# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ការប្រែក្លាយវិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិ ទៅជាសាកលវិទ្យាល័យសិល្បៈភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន



៥

https://www.moj.gov.kh/kh/law-regular

នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់ការប្រែក្លាយវិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិ ទៅជាសាកលវិទ្យាល័យសិល្បៈភ្នំពេញ ដែលសរសេរជាអក្សរកាត់ថា **ស.ស.ភ.** និងជាភាសាអង់គ្លេសថា Phnom Penh University of the Arts សរសេរជាអក្សរកាត់ថា PPUA។

**មាត្រា២ .-**

**ស.ស.ភ.** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានអាសយដ្ឋានអគារលេខ១៣៤អា ផ្លូវលេខ៥១ ភូមិ៥ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**ស.ស.ភ.** ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ដែលមានមហាវិទ្យាល័យចំនួន៥ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានសាលាក្រោយបរិញ្ញាបត្រចំនួន១ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

**១- មហាវិទ្យាល័យតូរ្យតន្ត្រី**

កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ក- ដេប៉ាតឺម៉ង់តន្ត្រី
- មុខជំនាញព្យាណូ
- មុខជំនាញឧបករណ៍ប្រើខ្យល់និងខ្សែ
- មុខជំនាញសូរសំនៀង។

ខ- ដេប៉ាតឺម៉ង់តន្ត្រីសម័យ
- មុខជំនាញសំនៀងសម័យ
- មុខជំនាញហ្គីតា។

គ- ដេប៉ាតឺម៉ង់និពន្ធតន្ត្រី
- មុខជំនាញនិពន្ធតន្ត្រី។



https://www.moj.gov.kh/kh/law-regular

**២- មហាវិទ្យាល័យគំនូរនិងរចនា**

កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ក- ដេប៉ាតឺម៉ង់ស្ថាបត្យកម្ម

- មុខជំនាញស្ថាបត្យកម្មនិងរចនាផ្ទៃខាងក្នុង។

ខ- ដេប៉ាតឺម៉ង់រចនាម៉ូតសម្លៀកបំពាក់

- មុខជំនាញរចនាម៉ូតសម្លៀកបំពាក់។

គ- ដេប៉ាតឺម៉ង់រចនាក្រាហ្វិក

- មុខជំនាញរចនាគំនូរសោរគមនាគមន៍។

**៣- មហាវិទ្យាល័យរបាំនិងល្ខោន**

កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ក- ដេប៉ាតឺម៉ង់របាំបាឡេ

- មុខជំនាញរបាំបាឡេ។

ខ- ដេប៉ាតឺម៉ង់របាំសម័យ

- មុខជំនាញក្បាច់រាំសម័យ។

គ- ដេប៉ាតឺម៉ង់ល្ខោន

- មុខជំនាញសម្តែងល្ខោន។

**៤- មហាវិទ្យាល័យអប់រំ**

កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ក- ដេប៉ាតឺម៉ង់អប់រំកុមារតូច

- មុខជំនាញអប់រំកុមារតូច។

ខ- ដេប៉ាតឺម៉ង់អប់រំភាសាអង់គ្លេស

- មុខជំនាញអប់រំភាសាអង់គ្លេស។

គ- ដេប៉ាតឺម៉ង់អប់រំភាសាកូរ៉េ

- មុខជំនាញអប់រំភាសាកូរ៉េ។

**៥- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន**

កម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

ក- ដេប៉ាតឺម៉ង់វិស្វកម្មសូហ្វែរ

- មុខជំនាញវិស្វកម្មសូហ្វែរ។

ខ- ដេប៉ាតឺម៉ង់ទូរគមនាគមន៍និងបណ្តាញ

- មុខជំនាញទូរគមនាគមន៍និងបណ្តាញ។

គ- ដេប៉ាតឺម៉ង់ពហុប្រព័ន្ធផ្សព្វផ្សាយ

- មុខជំនាញពហុប្រព័ន្ធផ្សព្វផ្សាយ។



https://www.moj.gov.kh/kh/law-regular

**៦- សាលាក្រោយបរិញ្ញាបត្រ**

កម្រិតបរិញ្ញាបត្រជាន់ខ្ពស់

- មុខជំនាញព្យាណូ
- មុខជំនាញឧបករណ៍ប្រើខ្យល់និងខ្សែ
- មុខជំនាញសូរសំនៀង
- មុខជំនាញអក្សរភ្លេង
- មុខជំនាញស្ថាបត្យកម្មនិងរចនាផ្ទៃខាងក្នុង
- មុខជំនាញរចនាម៉ូតសម្លៀកបំពាក់
- មុខជំនាញរចនាប្លង់។

**មាត្រា៤ .-**

**ស.ស.គ**. អាចផ្លាស់ប្តូរទីតាំង ប្តូរឈ្មោះ បង្កើតសាខាថ្មី មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី ឬរៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យថ្មី ក្រោយពីមានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

**ស.ស.គ**. មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងៗទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ស.គ**. ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

សាកលវិទ្យាធិការ **ស.ស.គ**. មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង **ស.ស.គ**. និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិត ការទទួលនិស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមកម្មវិធីសិក្សារបស់ **ស.ស.គ**. ព្រមទាំងបទដ្ឋាននិងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៧ .-**

និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយ **ស.ស.គ**. ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។



https://www.moj.gov.kh/kh/law-regular

**មាត្រា៨ .-**

អនុក្រឹត្យលេខ៤៨២ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការទទួលស្គាល់វិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យសិល្បៈភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៦កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular